# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

## កំណត់ហេតុ
## ស្តីពីសិក្ខាសាលាផ្សព្វផ្សាយ
## កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ
## នៅខេត្តស្វាយរៀង និងព្រៃវែង

ឆ្នាំពីរពាន់ប្រាំពីរ ខែកក្កដា ថ្ងៃទី ប្រាំមួយ វេលាម៉ោងប្រាំបី នៅសាលប្រជុំទីរួមខេត្តស្វាយរៀង មានរៀបចំសិក្ខាសាលាមួយ ក្រោមអធិបតីភាពឯកឧត្តម **សួង លាងហៃ** ទីប្រឹក្សាទីស្តីការគណៈរដ្ឋមន្ត្រី និងជានាយករងអង្គភាពគ្រប់គ្រងគម្រោង កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដែលគណៈរដ្ឋមន្ត្រីបានអនុម័តកាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥។ ចូល រួមជាគណៈធិបតីក្នុងឱកាសនោះមាន ឯកឧត្តម **តឹម ឆា** អភិបាលរងខេត្តស្វាយរៀង ឯកឧត្តម **ថង តឿន** អភិបាលរងខេត្តព្រៃវែង លោក **ថោ សារ៉ន** អនុប្រធានតុលាការខេត្តស្វាយរៀង និងលោក **តឹម អេង** អនុប្រធានតុលាការខេត្តព្រៃវែង។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ។

ជាកិច្ចចាប់ផ្តើមអង្គសិក្ខាសាលា ឯកឧត្តម **តឹម ឆា** អភិបាលរងខេត្តស្វាយរៀង បានសម្តែងកិច្ចស្វាគមន៍ចំពោះគណៈអធិបតី គណៈប្រតិភូនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ថ្នាក់ដឹកនាំ មន្ត្រីរាជការនៅតាមមន្ទីរ ជំនាញផ្សេងៗជុំវិញខេត្តស្វាយរៀង និងខេត្តព្រៃវែង ដែលមានវត្តមាននៅក្នុងអង្គសិក្ខាសាលា ព្រមទាំងថ្លែងអំណរគុណដល់អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹងធ្វើបទបង្ហាញជូនដល់មន្ត្រីរាជការ នៃអង្គភាពជំនាញផ្សេងៗរបស់ខេត្តឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀត អំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់ច្បាប់ និងតុលាការ។ ឯកឧត្តមបានបញ្ជាក់ថា អង្គសិក្ខាសាលានាពេលព្រឹកនេះ គឺត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយ និងចែករំលែកបទពិសោធន៍ផ្សេងៗនៃការកែទម្រង់ច្បាប់ និងតុលាការជូនមន្ត្រីរាជការក្នុងខេត្ត ក្នុងខណៈ ដែលរាជរដ្ឋាភិបាលកំពុងតែធ្វើដំណើរឆ្ពោះទៅមុខប្រកបដោយឆន្ទៈដ៏មោះមុត ជាមួយនឹងកម្មវិធីនយោបាយកំណែទម្រង់រដ្ឋ ដែលជាសមាសធាតុគន្លឹះនៃអភិបាលកិច្ចល្អស្នូលនៃយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលអាណត្តិទី៣នៃរដ្ឋសភា។

ជាបន្ទាប់ឯកឧត្តម **សួង លាងហៃ** បានធ្វើការបង្ហាញជូនអង្គសិក្ខាសាលាអំពីដំណើរការ នៃការកែទម្រង់ច្បាប់ និងតុលាការ និងការរៀបចំរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានបង្កើតឡើងនៅថ្ងៃ ទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និង ឯកឧត្តម **ឌិត មុន្ទី** ប្រធានតុលាការកំពូល ជាសហប្រធាន។ ឯកឧត្តមបានបង្ហាញជូនអង្គប្រជុំអំពីអង្គភាពផ្សេងៗ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលរួមមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (PCB) ដែលបានបង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ និងអង្គភាពគ្រប់គ្រងគម្រោង (PMU) ដែលបានបង្កើតឡើងនៅ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

ឯកឧត្តមបានបញ្ជាក់ជូនថា ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ មានបេសកកម្ម ផ្តួចផ្តើមជំរុញដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តន៍កម្មវិធីនយោបាយ និងកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការស្របតាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលមានសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជាប្រធាន។

ចំពោះការរៀបចំឯកសារក្របខណ្ឌ សម្រាប់អនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឯកឧត្តមប្រធានបានជម្រាបជូនអង្គប្រជុំថា មានការគិតគូរយ៉ាងច្បាស់លាស់ ហើយបានគ្រប់ជ្រុងជ្រោយ មានមូលដ្ឋានលើរដ្ឋធម្មនុញ្ញលើ តម្លៃជាតិ និងគោលការណ៍ជាអន្តរជាតិទៀតផង។

យើងមានចក្ខុវិស័យ មានគោលដៅ មានទិសដៅជាយុទ្ធសាស្ត្រទាំង៧ ហើយទីបញ្ចប់ គឺមានកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រទាំងនោះទៀត ដែលត្រូវបានបែងចែកទៅជារយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។

បន្ទាប់ពីបទបង្ហាញនេះមក លោក **ថោ សារ៉ន** អនុប្រធានតុលាការខេត្តស្វាយរៀងបានធ្វើចំណាប់អារម្មណ៍ជូនអង្គប្រជុំ។

លោក **ថោ សារ៉ន** បានអបអរចំពោះកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ របស់រាជរដ្ឋាភិបាល ដែលបានធ្វើឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃសេដ្ឋកិច្ចទីផ្សារសេរី និងដើម្បីពង្រឹងភាពជាដៃគូរវាងរដ្ឋាភិបាល និងផ្នែកឯកជន។

ទាក់ទងដល់ការកែទម្រង់ លោកបានលើកឡើងអំពីភាពចាំបាច់ក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាពិសេសមាត្រាទី៦ និងទី ៧ នៃច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ជាចុងក្រោយលោកអនុប្រធានតុលាការខេត្តស្វាយរៀងបានលើកឡើង ពីបញ្ហាកង្វល់មួយចំនួនរបស់តុលាការខេត្តស្វាយរៀងផ្ទាល់ដូចជា ៖

១-ការដាក់វិន័យចៅក្រមដែលធ្វើកំហុសឆ្គង គឺដាក់បានតែចៅក្រមថ្នាក់ទាបប៉ុណ្ណោះ ដូច្នេះធ្វើឱ្យគ្មានតម្លាភាព។

២-ចៅក្រមទាំងអស់ពុំទាន់មានច្បាប់ធានា និងការពារវិជ្ជាជីវៈ ក៏ដូចជាវាសនាអនាគតក្នុងប្រព័ន្ធអាជីព និងជីវភាពការងារ មូលហេតុគឺពុំទាន់មានលក្ខន្តិកៈសម្រាប់ចៅក្រម។

៣-កង្វល់ចុងក្រោយគឺពាក់ព័ន្ធទៅនឹងច្បាប់ថ្មី មានក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានការផ្លាស់ប្ដូរស្ទើរតែទាំងស្រុងពីច្បាប់ចាស់ ហើយមានការរៀនសូត្រវគ្គបំពាក់បំប៉នហើយ តែពុំទាន់មានរូបមន្តឱ្យបានច្បាស់លាស់ ដើម្បីចាត់ចែងការងារអនុវត្តទៅតាមនីតិវិធី។

ព្រមជាមួយគ្នានោះ លោកក៏បានជម្រាបជូនអង្គប្រជុំអំពី បញ្ហាកង្វះខាតថវិកាសម្រាប់ចំណាត់ការដំណើរការតុលាការនៅថ្នាក់មូលដ្ឋាន និងសំណូមពរដល់រាជរដ្ឋាភិបាលមេត្តាពិនិត្យឡើងវិញអំពីការកំណត់កញ្ចប់ថវិកាប្រចាំឆ្នាំ សម្រាប់យុត្តាធិការទូទាំងប្រទេស។

លោក **តឹម អេខ** អនុប្រធានតុលាការខេត្តព្រៃវែង បានសម្ដែងការពេញចិត្តចំពោះយុទ្ធសាស្ត្រទាំងប្រាំពីរ និងផែនការសកម្មភាពនៃកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ និងបានបង្ហាញពីទំនុកចិត្តរបស់លោកសម្រាប់ថ្ងៃអនាគតថា កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាលនឹង ៖

១-ធ្វើឱ្យមានភាពជឿនលឿនក្នុងការគោរព ការកែលំអ និងការថែរក្សាមុខមាត់បញ្ញតិច្បាប់

២-ធ្វើឱ្យប្រសើរឡើងនូវរបៀបរៀបរយសន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម

៣-ទាក់ទាញបាននូវជំនឿ និងសេចក្ដីទុកចិត្តពីសហគមន៍អន្តរជាតិទៅលើការទែម្រង់ច្បាប់ និងប្រព័ន្ធតុលាការ និងអាចទាក់ទាញវិនិយោគិនបរទេសឱ្យមានជំនឿទុកចិត្តទៅលើប្រព័ន្ធច្បាប់នៅកម្ពុជាយើង។

ឯកឧត្តម **ម៉ែន ម៉ុនឈរ** នាយករងអង្គភាពគ្រប់គ្រងគម្រោង បានធ្វើការបង្ហាញអំពីកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ តាមរយៈការបញ្ចាំងស្លាយដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធ។

បន្ទាប់ពីការបង្ហាញកម្មវិធីសកម្មភាព និងទិសដៅជាយុទ្ធសាស្ត្រ គឺជាវេទិកាសំណួរ ចម្លើយដែលទាក់ទងទៅនឹងការកែទម្រង់ច្បាប់ និងតុលាការ ។

លោក **ង៉ោ ហ៊ួរ** ប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង បានមានប្រសាសន៍ថា លោកមានការពេញចិត្ត និងចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះឯកឧត្តមនាយករងអង្គភាពគ្រប់គ្រងគម្រោង ដែលបានធ្វើបទបង្ហាញខាងលើ។ ប៉ុន្តែលោកមានចម្ងល់ថា ហេតុអ្វីបានជានៅក្នុងផែនការយុទ្ធសាស្ត្រទាំង៧ នៃការកែទម្រង់ច្បាប់ និងតុលាការនេះ ក្រសួងសុខាភិបាលដែលជាអ្នកធ្វើកោសល្យវិច័យ ធ្វើការពិសោធន៍ DNA ទាក់ទងករណីរំលោភសន្ថវៈ និងឃាតកម្មជាដើម មិនឃើញមានឈ្មោះពាក់ពន្ធ័។

ឯកឧត្តម **ស្ងួន ឈានហៃ** បានឆ្លើយតបទៅនឹងសំណួរនេះថា កម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការពាក់ព័ន្ធគ្រប់ក្រសួងស្ថាប័នទាំងអស់ នៃរាជរដ្ឋាភិបាល។ ហើយសកម្មភាពទាំងឡាយត្រូវបានចងក្រងទៅតាមយុទ្ធសាស្ត្រ និងទៅតាមអាទិភាព។ យើងមិនអាចលើកយកសកម្មភាពទាំងអស់មកធ្វើក្នុងពេលតែមួយបានទេ យើងត្រូវយកអ្វីដែលជាអាទិភាពសំខាន់បំផុតមកធ្វើមុនគេ ហើយជាបន្តបន្ទាប់តាមលំដាប់លំដោយតទៅទៀត។ ទាក់ទងនឹងការងារសុខាភិបាល ឯកឧត្តមបានបញ្ជាក់ជូនថា គម្រោងជំនួយ CCJAP III របស់ AusAID បាន គិតគូររួចហើយ ជាពិសេសខាងការធ្វើកោសល្យវិច័យនេះ ព្រោះវាមានសារៈសំខាន់ណាស់ សម្រាប់កម្មវិធីយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា។ គម្រោងនេះស្ថិតក្នុងទិសដៅជាយុទ្ធសាស្ត្រទី៥ សកម្មភាព ៥.៣.២ ទាក់ទងដល់ការបង្កើតតុលាការគំរូ។ ឯកឧត្តមបានបំភ្លឺថា គ្មានសកម្មភាពណាមួយដែលជះឥទ្ធិពលដល់ការកែទម្រង់ច្បាប់ និងតុលាការ មិនត្រូវបានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មិនគិតគូរនោះឡើយ គ្រាន់តែថា សកម្មភាពនោះមិនបានរំលេចចេញ តែមានដាក់បង្កប់នៅក្នុងសកម្មភាពណាមួយផ្សេងទៀត។

លោក **គឹម អេង** អនុប្រធានតុលាការខេត្តព្រៃវែង បានមានចំណាប់អារម្មណ៍លើពីរចំណុច ៖

ចំណុចទី១ ទាក់ទងទៅនឹងយុទ្ធសាស្ត្រទី១ គឺ ការពង្រឹងការពារសិទ្ធិសេរីភាពបុគ្គល លោកបានមានប្រសាសន៍ថា ការបង្កើតអាជ្ញាធរជាតិ ដើម្បីដោះស្រាយវិវាទដីធ្លីបន្ថែមពីលើគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ថ្នាក់ស្រុក រួមទាំង តុលាការខេត្ត ក្រុង និងសាលាឧទ្ធរណ៍ សរុបទៅមានដល់ ៦ ថ្នាក់ គិតទៅខាតពេលវេលាច្រើន។ ដូច្នេះលោកសុំស្នើឱ្យមានការកាត់បន្ថយនីតិវិធី ឬក៏មានការកែប្រែនីតិវិធី និងកំណត់ឱ្យបានច្បាស់លាស់ថាបញ្ហាកំរិតណា ដែលត្រូវដោះស្រាយត្រឹមថ្នាក់ស្រុក ឬថ្នាក់ខេត្ត រួចត្រឹមណាវុញទៅតុលាការ។ ធ្វើដូច្នេះបាន គឺយើងអាចកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋបានមួយកំរិត។ លោកក៏បានសំណូមពរផងដែរថា បើមានវិវាទដីធ្លីតូចតាច សូមឱ្យធ្វើការដោះស្រាយត្រឹមថ្នាក់ស្រុក ឬខេត្តបានហើយ។

ចំណុចទី២ ទាក់ទងទៅនឹងយុទ្ធសាស្ត្រទី៣ គឺ ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋបានទទួលចំណេះដឹងផ្នែកច្បាប់ និងធ្វើការផ្សព្វផ្សាយច្បាប់ជាសាធារណៈដល់ប្រជាពលរដ្ឋ។ លោកបានលើកឧទាហរណ៍ទាក់ទងនឹងករណីរំលោភសន្ធវៈឬឃាតកម្មថា គួរថតជាវីឌីអូ ដើម្បីបង្ហាញមុខជនជាប់ចោទឱ្យប្រជាពលរដ្ឋបានឃើញ និងដឹងឮក្នុងពេលជំរះក្តី។ បន្ទាប់ពីជំរះក្តីរួច យើងត្រូវតែផ្សព្វផ្សាយព្រោះជារឿងពិត ហើយយើងទុកជាឯកសារផងដែរ។

ឯកឧត្តម **ស្ងួន ឈានហៃ** បានធ្វើការបំភ្លឺថា អង្គភាពនីមួយៗខាងលើមានភារកិច្ចផ្សេងៗមិនជាន់គ្នាទេ។ គណៈកម្មាការសុរិយោដីគ្រប់ជាន់ថ្នាក់បំពេញតួនាទីខាងរដ្ឋបាល រៀបចំបណ្ណ័កម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ ចំណែកឯករណីប្តឹងផ្តល់ គឺជាតួនាទីរបស់តុលាការដែលត្រូវដោះស្រាយ។ រីឯអាជ្ញាធរជាតិ គឺដោះស្រាយវិវាទដីធ្លីធំៗ ដែលខេត្តមិនអាចដោះស្រាយបាន ហើយមានការពាក់ព័ន្ធជាមួយសមត្ថកិច្ចច្រើន។

ចំពោះការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ ឯកឧត្តមបានបញ្ជាក់ថា យើងមានអគ្គនាយកដ្ឋានរាជកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានធ្វើការបោះពុម្ពច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងៗជារៀងរាល់សប្តាហ៍ ដើម្បីធ្វើការចែកផ្សព្វផ្សាយ។ ក្រសួងមហាផ្ទៃក៏បានទិញរាជកិច្ចនេះធ្វើការចែកចាយដល់ថ្នាក់មូលដ្ឋានភូមិ ឃុំផងដែរនៅតែមានកំរិតនៅឡើយ។

ចំពោះសាលដីកា ក៏មានធ្វើការបោះពុម្ពផ្សព្វផ្សាយដែរ សព្វថ្ងៃនេះប្រមូលចងក្រង ដោយក្រុមការងារខាងតុលាការកំពូល និងបោះផ្សាយដោយអគ្គនាយកដ្ឋានរាជកិច្ច។

ទាក់ទងនឹងការផ្សព្វផ្សាយការជំរះក្តីតាមទូរទស្សន៍ ឯកឧត្តម **ម៉ែន ម៉ុនឈា** នាយករងអង្គភាពគ្រប់គ្រងគម្រោងបានលើកឡើងថា វាអាចប៉ះពាល់ដល់ផលប្រយោជន៍ កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ភាគី។

លោក **ម៉ុំ ចន្ទ័តារា** អនុប្រធានមន្ទីរធម្មការខេត្តព្រៃវែង បានលើកឡើងពីសំណុំរឿងដែលសល់គរនៅតុលាការ ដោយផ្តល់ជាយោបល់ថា ត្រូវដោះស្រាយទៅតាមសំណុំរឿង និងតាមកំរិតជាន់ថ្នាក់ និងចោទសួរថា តើវិវាទណាដែលត្រូវដោះស្រាយនៅថ្នាក់ភូមិ ឃុំ?

ឯកឧត្តម **សួង លាងហៃ** បានស្រាយបំភ្លឺ ចំពោះបញ្ហាសំណុំរឿងដែលសល់គរនៅតុលាការនេះថា រាជរដ្ឋាភិបាល មិនបានព្រងើយកន្តើយចំពោះបញ្ហានេះឡើយ។ នៅក្នុងកម្មវិធីសកម្មភាពសម្រាប់យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការបញ្ហានេះ គឺជាបញ្ហាប្រឈមមុខដែលត្រូវដោះស្រាយជាបន្ទាន់ ហើយវិធានការមួយចំនួនត្រូវបានដាក់ចុះ រីឯលទ្ធផលដែលទទួលបានក៏គួរជាទីមោទនៈដែរ។ ចំពោះការដោះស្រាយវិវាទនៅថ្នាក់ភូមិ ឃុំ យើងកំពុងតែអនុវត្ត គម្រោងសិទ្ធិទទួលបានយុត្តិធម៌ (A2J) ក្រោមការឧបត្ថម្ភគាំទ្ររបស់អង្គការ UNDP ដើម្បីសិក្សាអំពីបញ្ហាបញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះក្នុងការដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន។

នៅទីបញ្ចប់ឯកឧត្តម **សួង លាងហៃ** បានធ្វើការបូកសរុបលទ្ធផលនៃការពិភាក្សា និងបានធ្វើការសន្យាថា នឹងស្រង់នូវគំនិតយោបល់ល្អៗរបស់អង្គសិក្ខាសាលា ទៅធ្វើការពិចារណាក្នុងការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការឱ្យបានកាន់តែប្រសើរឡើងទៀត។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៧*

**បានឃើញ និងឯកភាព**

គណៈធិបតីនៃអង្គសិក្ខាសាលា

សួង លាងហៃ

**អ្នកធ្វើរបាយការណ៍**

សេង វ៉ាន់ដា ស៊ិន សិរីវុធ